# ការថែរក្សានូវការផ្លាស់ប្តូរដ៏ធំក្នុងដួងចិត្ត

អែលឌើរ ឌែល ជី រ៉េងឡាន់
នៃពួក 70 នាក់

*ដើម្បីស៊ូទ្រាំដល់ចុងបំផុត នោះយើងត្រូវមានបំណងប្រាថ្នាធ្វើឲ្យព្រះសព្វព្រះទ័យ ហើយថ្វាយបង្គំទ្រង់ដោយសេចក្តីក្លៀវក្លា ។*

នៅក្នុងខែ ធ្នូ ឆ្នាំ 1967 ការវះកាត់ផ្លាស់ប្តូរបេះដូងដ៏ជោគជ័យជាលើកដំបូង ត្រូវបានធ្វើឡើងនៅក្នុងក្រុងកាប៉េ ប្រទេសអាហ្វ្រិចខាងត្បូង ។ បេះដូងដែលមានជម្ងឺរបស់បុរសជិតស្លាប់ម្នាក់ ត្រូវបានគេវះកាត់យកចេញ ហើយត្រូវបានដេរជំនួសវិញដោយបេះដូងដែលមានសុខភាពល្អ ដែលបានបរិច្ចាគដោយអ្នកស្លាប់ម្នាក់ ។ ចាប់តាំងពីពេលនោះមក មានការវះកាត់ផ្លាស់ប្តូរបេះដូងច្រើនជាង 75,000 លើក ត្រូវបានធ្វើឡើងនៅជុំវិញពិភពលោក ។

នៅក្នុងខ្លួនរបស់ពួកអ្នកទទួលយកការវះកាត់ផ្លាស់ប្តូរបេះដូង រូបកាយពួកគេបានស្គាល់ បេះដូងដែលសង្គ្រោះជីវិត គឺជា "សរីរាង្គថ្មី" ហើយបានចាប់ផ្តើមលោត ។ បើមិនបានធ្វើអ្វីមួយដើម្បីការពារវានោះទេ នោះប្រតិកម្មពីធម្មជាតិរបស់ រាងកាយនឹងបដិសេធបេះដូងថ្មីនោះ ហើយអ្នកជម្ងឺនោះនឹងស្លាប់ ។ ថ្នាំជាច្រើនអាចទប់ស្កាត់ប្រតិកម្មពីធម្មជាតិនេះបាន ប៉ុន្តែការប្រើថ្នាំនោះ ត្រូវតែមានជាប្រចាំថ្ងៃ និងតាមពេលកំណត់ឲ្យបានត្រឹមត្រូវបំផុត ។ ជាងនេះទៀត ស្ថានភាពរបស់បេះដូងថ្មីត្រូវតែមានការត្រួតពិនិត្យ ។ ការពិសោធន៍មើលបេះដូងម្តងម្កាលត្រូវបានធ្វើឡើង ដោយការកាត់យកបំណែកតូចមួយនៃជាសិកាបេះដូង រួចហើយយកទៅធ្វើរោគវិនិច្ឆ័យដោយអតិសុខុមទស្សន៍ ។ នៅពេលសញ្ញានៃការបដិសេធត្រូវបានគេរកឃើញ នោះការប្រើប្រាស់ថ្នាំត្រូវមានការកែសំរួល ។ បើដំណើរការនៃការបដិសេធនោះរកឃើញទាន់ពេល នោះសេចក្តីស្លាប់អាចត្រូវបានគេបង្វៀងបាន ។

គួរឲ្យភ្ញាក់ផ្អើល មានអ្នកជម្ងឺមួយចំនួនបានធ្វេសប្រហែសចំពោះបេះដូងដែលបានវះកាត់ផ្លាស់ថ្មីរបស់ខ្លួនទៅវិញ ។ ពួកគេបានផ្អាកទទួលទានថ្នាំជាច្រើនលើក ហើយមិនបានទៅពិនិត្យឲ្យបានញឹកញាប់តាមដែលពួកគេគួរធ្វើនោះទេ ។ ពួកគេបានគិតថា ដោយសារពួកគេមានអារម្មណ៍ល្អ នោះពួកគេបានប្រសើរឡើងហើយ ។ ជាញឹកញាប់ ឥរិយាបថមើលស្រាលនេះបានធ្វើឲ្យអ្នកជម្ងឺទាំងនោះជួបហានិភ័យ និងកាត់បន្ថយដល់អាយុជីវិតរបស់ខ្លួន ។

ការវះកាត់ផ្លាស់ប្តូរបេះដូងអាចពន្យាជីវិតបានច្រើនឆ្នាំដល់ពួកអ្នកដែលអាចស្លាប់ដោយសារជម្ងឺគាំងបេះដូងបាន ។ ប៉ុន្តែ នៅក្នុងឆ្នាំ 1967 ទស្សនាវដ្តី *ថែម* បានហៅដំណើរការនេះថា ពុំមែនជា "ការវះកាត់ដ៏ជោគជ័យបំផុតនោះទេ" ។ 1 ការវះកាត់ដ៏ជោគជ័យបំផុត គឺពុំមែនជាការវះកាត់ខាងរូបកាយនោះទេ ប៉ុន្តែវាគឺជា "ការផ្លាស់ប្តូរដ៏ធំក្នុងដួងចិត្ត" ខាងវិញ្ញាណវិញ ។ 2

តាមរយៈដង្វាយធួនរបស់ព្រះគ្រីស្ទ និងដោយការគោរពប្រតិបត្តិចំពោះក្រឹត្យវិន័យ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ នោះយើងនឹងទទួលអារម្មណ៍នៃការវះកាត់ដ៏ជោគជ័យបំផុតនេះ ដែលជាការផ្លាស់ប្តូរក្នុងដួងចិត្តខាងវិញ្ញាណ ។ ជាលទ្ធផលនៃអំពើរំលងរបស់យើង នោះដួងចិត្តខាងវិញ្ញាណរបស់យើងមានជម្ងឺ ហើយរឹងរូស ដោយធ្វើឲ្យយើងទទួលរងនូវសេចក្តីស្លាប់ខាងវិញ្ញាណ និងការបែកចេញពីព្រះវរបិតាសួគ៌របស់យើង ។ ព្រះអម្ចាស់បានពន្យល់ពីការវះកាត់ ដែលយើងរាល់គ្នាត្រូវការថា : "យើងនឹងឲ្យឯង

មានចិត្តថ្មី ហើយនឹងដាក់វិញ្ញាណថ្មីនៅក្នុងឯងដែរ យើងនឹងដកយកចិត្ត ដែលរឹងដូចថ្មីពីរូបសាច់ឯងចេញ រួចនឹងឱ្យមានចិត្តជាសាច់វិញ"។13

ទោះជាយ៉ាងណា ការផ្លាស់ប្តូរដ៏ធំក្នុងដួងចិត្តខាងវិញ្ញាណរបស់យើង គឺគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ ដូចគ្នានឹងពួកអ្នកជម្ងឺធ្វើការវះកាត់ផ្លាស់ប្តូរបេះដូងដូច្នោះដែរ។ ការប្រែចិត្ត បុណ្យជ្រមុជទឹក និងការបញ្ជាក់ គឺជារឿងចាំបាច់ ប៉ុន្តែវាមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ជាការពិតណាស់ បើយើងចង់កាន់ខ្ជាប់ដរាបដល់ចុងបំផុត នោះយើងត្រូវ ខ្វល់ខ្វាយចំពោះការផ្លាស់ប្តូរក្នុងដួងចិត្តខាងវិញ្ញាណឱ្យស្មើនឹងការផ្លាស់ប្តូរបេះដូងខាងសាច់ឈាម បើមិនអាចធ្វើអ្វីបាន ប្រសើរជាងនេះនោះ។ មានតែធ្វើបែបនេះទេ ទើបយើងអាចនឹងចាត់ថាគ្មានទោសនៅគ្រានៃការកាត់សេចក្តី។14

ការកាន់ខ្ជាប់ដរាបដល់ចុងបំផុតអាចក្លាយជារឿងដ៏លំបាក ពីព្រោះនិន្នាការរបស់មនុស្សខាងសាច់ឈាម គឺមាន ការបដិសេធចំពោះការផ្លាស់ប្តូរក្នុងដួងចិត្ត ហើយបណ្តោយឱ្យវាមានភាពរឹងរូស។ គ្មានការងឿងឆ្ងល់ទេដែល ព្រះអម្ចាស់បានព្រមានអំពីការល្បួង "... ចូរឱ្យអស់អ្នកណាដែលបានញែកចេញជាបរិសុទ្ធប្រយ័ត្នផងចុះ"។15

យើងទាំងអស់គ្នាបានស្គាល់បុគ្គលជាច្រើនដែលមានការប្រែចិត្តដ៏ធំនេះ ប៉ុន្តែក្រោយមកបានងាកទៅរកលក្ខណៈជាមនុស្សខាងសាច់ឈាមវិញ។ ពួកគេបានធ្វេសប្រហែសចំពោះការថ្វាយបង្គំ និងការលះបង់របស់ខ្លួនចំពោះព្រះ។ ដួងចិត្តរបស់ពួកគេចាប់ផ្តើមរឹងរូស ហេតុដូច្នេះហើយ ពួកគេបានធ្វើឱ្យអន្តរាយដល់សេចក្តីសង្គ្រោះដ៏នៅអស់កល្បជានិច្ចរបស់ខ្លួន។

ជីវិតរបស់ពួកអ្នកដែលត្រូវបានផ្លាស់ប្រែចិត្តជឿដោយការបង្រៀនរបស់ពួកបុត្រានៃម៉ូសាយ បានផ្តល់ជាចំណេះដឹងមួយចំនួនពីរបៀបដែលមនុស្សម្នាក់អាចជៀសវាងពីការបដិសេធចំពោះការផ្លាស់ប្តូរក្នុងដួងចិត្តខាងវិញ្ញាណ។ យើងអានពីពួកគេថា "មានមនុស្សជាច្រើនដែលត្រូវបាននាំមកឱ្យស្គាល់សេចក្តីពិតតាមរយៈការបង្រៀនរបស់អាំម៉ូន និងបងប្អូន លោក... ហើយបានមករកព្រះអម្ចាស់ នោះពួកគេពុំបោះបង់ចោលសាសនាឡើយ"។16

តើពួកគេមានជោគជ័យ នៅក្នុងការកាន់ខ្ជាប់ដល់ចុងបំផុតបានដោយរបៀបណា? យើងបានដឹងថា ពួកគេ "មានចិត្តឧស្សាហ៍ដល់ព្រះ និងដល់មនុស្សលោកផង ព្រោះពួកគេមានចិត្តទៀងត្រង់ និង សុចរិតដោយឥតខ្ចោះ ក្នុងគ្រប់ការណ៍ទាំងអស់ ហើយពួកគេមានចិត្តរឹងប៉ឹងនៅក្នុងសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ គឺរហូតដល់ចុង បំផុត"។17

ចិត្តឧស្សាហ៍ដល់ព្រះរបស់ពួកគេ ប្រហែលជាឆ្លុះបញ្ចាំងពីបំណងប្រាថ្នាចង់ធ្វើឱ្យព្រះសព្វព្រះទ័យ ហើយថ្វាយបង្គំទ្រង់ ដោយការពេញចិត្ត និងភាពក្លៀវក្លា។ ចិត្តឧស្សាហ៍របស់ពួកគេចំពោះមនុស្សលោក បានណែនាំពីចំណាប់អារម្មណ៍ដ៏ ឧស្សាហ៍មួយនៅក្នុងការជួយ និងបំរើដល់មនុស្សដទៃទៀត។ ការមានចិត្តទៀងត្រង់ និងសុចរិតដោយឥតខ្ចោះនៅក្នុងគ្រប់ការណ៍ទាំងអស់បានណែនាំថា ពួកគេមានចិត្តរឹងប៉ឹងចំពោះសេចក្តីសញ្ញារបស់ខ្លួន និងមិនកាត់បន្ថយការតាំងចិត្តរបស់ពួកគេចំពោះព្រះ ឬមនុស្សលោកឡើយ។ ជាងនេះទៀត យើងបានដឹងថា ពួកគេបានបង្រៀនដំណឹងល្អដល់កូនចៅរបស់ខ្លួននៅក្នុងផ្ទះ។ យើងបានដឹងថា ប្រជាជនទាំងនោះ បានកប់គ្រឿងចម្បាំងរបស់ខ្លួន ដោយដកយកការល្បួងចេញពីជីវិត។

ជាញឹកញាប់ ពួកគេត្រូវប៉ាន់ប្រមាណពីស្ថានភាពនៃការផ្លាស់ប្តូរក្នុងដួងចិត្តខាងវិញ្ញាណរបស់ខ្លួន។ ពួកគេមិនបានសន្មត់ ដោយសាមញ្ញថា អ្វីៗគ្រប់យ៉ាងមានភាពប្រសើរនោះទេ។ តាមរយៈការសិក្សាពីការផ្លាស់ប្តូរដួងចិត្តរបស់ខ្លួនជាទៀងទាត់ នោះពួកគេអាចដឹងជាមុនពីភាពរឹងរូស ឬការបដិសេធចំពោះការផ្លាស់ប្តូរនោះ ហើយកែតំរូវវា។

អាលម៉ាជាកូនបានសួរនូវសំណួរមួយចំនួនទៅកាន់ក្រុមប្រជាជនរបស់អាំម៉ូន ដែលជានិមិត្តរូបចំពោះការសិក្សានៃការផ្លាស់ប្តូរក្នុងដួងចិត្តខាងវិញ្ញាណ។ អាលម៉ាបានសួរថា "បើសិនជាអ្នករាល់គ្នាបានស្គាល់ការផ្លាស់ប្តូរនៅក្នុងដួងចិត្តអ្នក ហើយបើសិនជាអ្នករាល់គ្នាបានចាប់អារម្មណ៍ចង់ច្រៀងនូវចម្រៀងនៃសេចក្តីស្រឡាញ់ដែលប្រោសលោះ ខ្ញុំសូមសួរថា តើអ្នករាល់គ្នាអាចចាប់អារម្មណ៍យ៉ាងនេះឥឡូវនេះទេ?" គាត់បានសួរបន្ថែមទៀតថា តើពួកគេបាន បន្ទាបខ្លួនគ្រប់គ្រាន់ហើយឬនៅ ហើយរលាស់ចោលនូវការឆ្មើងឆ្មៃ និងចិត្តច្រណែន ហើយមានសណ្តានចិត្តចំពោះ បងប្អូនពួកគេហើយឬនៅ។ 9 តាមរយៈការឆ្លើយសំណួរបែបនេះដោយស្មោះត្រង់ នោះយើងអាចកែតំរូវការចេញពីផ្លូវត្រង់នឹងចង្អៀតបានទាន់ពេល ហើយអាចរក្សានូវសេចក្តីសញ្ញារបស់យើងដោយចិត្តរឹងប៉ឹង។

នៅក្នុងឆ្នាំ 1980 គ្រួសាររបស់យើងបានផ្លាស់ទីលំនៅទៅនៅទល់មុខនឹងមន្ទីរពេទ្យដែលខ្ញុំទទួលការបំពាក់បំប៉ន និងធ្វើការ។ ខ្ញុំបានធ្វើការជារៀងរាល់ថ្ងៃ រួមទាំង ថ្ងៃអាទិត្យផងដែរ។ បើ ខ្ញុំបញ្ចប់ការងារថ្ងៃអាទិត្យរបស់ខ្ញុំត្រឹមម៉ោង 2:00 រសៀល នោះខ្ញុំអាចចូលរួមជាមួយនឹងភរិយា ព្រមទាំងកូនស្រីរបស់ខ្ញុំ ធ្វើដំណើរទៅកាន់ការប្រជុំរបស់សាសនាចក្រ ដែលចាប់ផ្តើមនៅម៉ោងពី 2:30។

មានថ្ងៃអាទិត្យមួយ នៅចុងបញ្ចប់នៃការបំពាក់បំប៉នសំរាប់ឆ្នាំទីមួយរបស់ខ្ញុំ នោះខ្ញុំបានដឹងថា ប្រហែលជាខ្ញុំនឹងបញ្ចប់ នៅម៉ោងពី 2:00 ប៉ុន្តែខ្ញុំបានគិតថា ខ្ញុំត្រូវនៅក្នុងមន្ទីរពេទ្យឱ្យយូរជាងនេះបន្តិចទៀត ចាំរហូតដល់ភរិយា និងកូនស្រីរបស់ខ្ញុំចេញទៅព្រះវិហារបាត់សិន។ បន្ទាប់មក ខ្ញុំអាចដើរទៅផ្ទះ ហើយសំរាកតាមចិត្ត។ ខ្ញុំនឹកស្តាយដោយ និយាយថា ខ្ញុំពិតជាបានធ្វើដូច្នោះមែន។ ខ្ញុំបានរង់ចាំរហូតដល់ម៉ោង 2:15 ហើយបានដើរយឺតៗទៅផ្ទះវិញ ហើយបានសំរាកមួយស្របក់នៅលើសាឡុង។ ប៉ុន្តែខ្ញុំដេកមិនលក់នោះឡើយ។ ខ្ញុំបានទទួលការរំខាន ហើយមានចិត្តខ្វល់ខ្វាយ។ ជានិច្ចកាល ខ្ញុំតែងតែចូលចិត្តទៅកាន់ព្រះវិហារ។ ខ្ញុំងឿងឆ្ងល់ថាតើហេតុអ្វីនៅថ្ងៃនេះ ភ្លើងនៃទីបន្ទាល់ និងភាពក្លៀវក្លាដែលធ្លាប់មានការពីមុនកំពុងតែរលត់។

ខ្ញុំមិនបាច់ចាំគិតវែងឆ្ងាយនោះទេ។ គឺដោយសារតែកាលវិភាគរបស់ខ្ញុំ ទើបខ្ញុំមានការធ្វេសប្រហែសចំពោះការអធិស្ឋាន និងការសិក្សាព្រះគម្ពីររបស់ខ្ញុំ។ នាព្រឹកមួយ ខ្ញុំបានក្រោកឡើង ហើយបានអធិស្ឋាន រួចហើយចេញទៅធ្វើការ។ ជាញឹកញាប់ ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំតែងត្រឡប់មកផ្ទះវិញនៅយប់ជ្រៅ។ នោះខ្ញុំបានអស់កម្លាំងជាខ្លាំង រហូតដល់ខ្ញុំបានដេកលក់ពីមុនធ្វើការអធិស្ឋាន ឬការអានព្រះគម្ពីររបស់ខ្ញុំ។ លុះស្អែកឡើងដំណើរការនេះបានចាប់ផ្តើមម្តងទៀត។ បញ្ហានោះគឺថា ខ្ញុំមិនបានធ្វើនូវរឿងចាំបាច់ដែលខ្ញុំគួរធ្វើ ដើម្បីរក្សាការផ្លាស់ប្រែដួងចិត្តដ៏ធំរបស់ខ្ញុំ កុំក្លាយទៅជាមានភាពរឹងរូសនោះទេ។

ខ្ញុំបានក្រោកចេញពីលើសាឡុងនោះ ហើយបានលុតជង្គង់ចុះ រួចហើយបានទូលអង្វរសុំការអភ័យទោសពីព្រះ។ ខ្ញុំបានសន្យានឹងព្រះវរបិតាសួគ៌របស់ខ្ញុំថា ខ្ញុំនឹងកែខ្លួន។ នៅថ្ងៃបន្ទាប់ ខ្ញុំយកព្រះគម្ពីរមរមនទៅកាន់មន្ទីរពេទ្យ។ នៅលើតារាង "កិច្ចការដែលត្រូវធ្វើ" របស់ខ្ញុំសំរាប់ថ្ងៃនោះ និងសំរាប់ជារៀងរាល់ថ្ងៃចាប់ពីពេលនោះមក គឺមាននូវកិច្ចការពីរយ៉ាង គឺការអធិស្ឋានឱ្យបានយ៉ាងហោចណាស់នៅពេលព្រឹក និងពេលយប់ ព្រមជាមួយនឹងការអានព្រះគម្ពីរផងដែរ។ ជួនកាល នៅពេលយប់ជ្រៅបានខិតចូលមកដល់ នោះខ្ញុំបានប្រញាប់ប្រញាល់រកកន្លែងស្ងាត់មួយ ដើម្បី អធិស្ឋាន។ មានថ្ងៃខ្លះ ការសិក្សាព្រះគម្ពីររបស់ខ្ញុំគឺមានរយៈពេលខ្លី។ ខ្ញុំក៏បានសន្យានឹងព្រះវរបិតាសួគ៌របស់ខ្ញុំថា ខ្ញុំនឹងព្យាយាមទៅព្រះវិហារជានិច្ច ទោះជាខ្ញុំមិនបានចូលរួមនៅក្នុងការប្រជុំមួយចំនួនក្តី។ ប៉ុន្មានសប្តាហ៍ក្រោយមក ភាពក្លៀវក្លានោះបានត្រឡប់មកវិញ ហើយភ្លើងនៃទីបន្ទាល់បានចាប់ផ្តើមឆេះយ៉ាងសន្ធោសន្ធៅជាថ្មីម្តងទៀត។ ខ្ញុំបានសន្យាថា នឹងមិនបណ្តោយឱ្យខ្លួនធ្លាក់ចូលទៅក្នុងអន្ទាក់នៃសេចក្តីស្លាប់ខាងវិញ្ញាណ ដោយការធ្វេសប្រហែសចំពោះរឿងទាំងនេះដែលមើលទៅថាជារឿងតូចតាចនោះ ហើយឱ្យអន្តរាយដល់រឿងដ៏នៅអស់កល្បជានិច្ចទៀតឡើយ ទោះជាស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ។

ដើម្បីស៊ូទ្រាំដល់ចុងបំផុត នោះយើងត្រូវមានបំណងប្រាថ្នាធ្វើឱ្យព្រះសព្វព្រះទ័យ នេះមានន័យថា យើងរក្សាសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទដោយការអធិស្ឋាន ការសិក្សាព្រះគម្ពីរ ការទទួលទានសាក្រាម៉ង់រៀងរាល់សប្តាហ៍ និងការមានព្រះវិញ្ញាណ-បរិសុទ្ធជាដៃគូដ៏ខ្ជាប់ខ្ជួនរបស់យើង។ យើងត្រូវចេះជួយ ហើយបំរើដល់មនុស្សដទៃឱ្យបានក្លៀវក្លា ហើយចែកចាយដំណឹងល្អជាមួយនឹងពួកគេ។ យើងត្រូវមានភាពស្មោះត្រង់ឱ្យល្អឥតខ្ចោះនៅគ្រប់រឿងទាំងអស់ ហើយមិនត្រូវ លេបសម្តីចំពោះសេចក្តីសញ្ញារបស់យើងជាមួយនឹងព្រះ ឬការតាំងចិត្តរបស់យើងចំពោះមនុស្សដទៃឡើយ ទោះជាស្ថិត នៅក្នុងស្ថានភាពណាមួយក៏ដោយ។ នៅក្នុងផ្ទះរបស់យើង យើងត្រូវនិយាយ អររីករាយ ហើយផ្សាយអំពីព្រះគ្រីស្ទ ដើម្បីឱ្យកូនចៅរបស់យើង---ព្រមទាំងខ្លួនយើងផងដែរ---មានបំណងប្រាថ្នាយកដង្វាយធួន មកអនុវត្តនៅក្នុងជីវិតរស់ នៅរបស់យើង។ 10 យើងត្រូវតែស្គាល់ការល្បួងថាវាចោមរោមយើងយ៉ាងងាយ ហើយដាក់នៅយ៉ាងឆ្ងាយ និងមិនអាចយោងដល់។ ទីបំផុត យើងត្រូវបន្តពិសោធការផ្លាស់ប្រែដួងចិត្តដ៏ធំរបស់យើង ហើយផ្លាស់ប្តូរនូវរាល់សញ្ញានៃការបដិសេធកាលពីមុន។

សូមពិចារណាពីស្ថានភាពនៃការផ្លាស់ប្រែចិត្តរបស់អ្នក។ តើអ្នករាល់គ្នាបានការពាររាល់មជ្ឈដ្ឋាននៃការបដិសេធដែលកើតមានដោយសារនិន្នាការនៃមនុស្សខាងសាច់ឈាម ដែលបណ្តាលឱ្យមានការធ្វេសប្រហែសនោះដែរឬទេ? បើដូច្នេះមែន សូមស្វែងរកទីកន្លែងមួយដែលអ្នករាល់គ្នាអាចលុតជង្គង់បានផងដែរ។ សូមចងចាំថា ជីវិតរមែងស្លាប់ នៅលើផែនដីនេះ គឺពុំមានរយៈពេលយូរនោះទេ។ សូមកុំប្រថុយរហូតដល់បាត់បង់នូវផលផ្លែនៃ ការវះកាត់ដ៏ ជោគជ័យបំផុត ដែលជា : សេចក្តីសង្គ្រោះ និងភាពដំកើងឡើងដ៏នៅអស់កល្បជានិច្ចនោះឡើយ។

ខ្ញុំសូមអធិស្ឋានថា យើងនឹងអាចអនុវត្តសេចក្តីជំនឿដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ និងកាន់ខ្ជាប់ដល់ចុងបំផុតដោយរីករាយ 11 នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. "Surgery: The Ultimate Operation" *Time* ថ្ងៃទី 15 ខែ ធ្នូ ឆ្នាំ 1967 ទំព័រ 64 ។

2. សូមមើល ម៉ូសាយ 5:2 អាលម៉ា 5:12--14 ។

3. អេសេគាល 36:26 ។

4. សូមមើល នីហ្វៃទី 3 27:16 ។

5. គ. និង ស. 20:34 ។

6. អាលម៉ា 23:6 ។

7. អាលម៉ា 27:27 ។

8. អាលម៉ា 5:26 ។

9. សូមមើល អាលម៉ា 5:27--30 ។

10. សូមមើល នីហ្វៃទី 2 25:26 ។

11. សូមមើល Dieter F. Uchtdorf "Have We Not Reason to Rejoice?" *Liahona* Nov. 2007 ទំព័រ 18--21 ។